របស់ខ្លួន នៅលើពាក្យសុំផលកម្រៃម្ហូបអាហារផងដែរ ឬមួយក៏ សរសេរថា “none”

ប្រសិនបើមនុស្សធំពេញវ័យនោះ គ្មានលេខ SOCIAL SECURITY ទេនោះ ។

<u>សម្រាប់កូនក្មេងដែលចុះឈ្មោះនៅក្នុងមជ្ឈមណ្ឌលថែទាំកូនក្មេង:</u>

សូមបំពេញ រួចហើយចុះហត្ថលេខា បន្ទាប់មកផ្ញើរសំណុំពាក្យសុំផលកម្រៃម្ហូបអាហារនេះ (Meal Benefit Form) ឲ្យបានឆាប់រហ័សបំផុត ដែលអាចធ្វើទៅបាន ។ ក្មេងៗទាំងអស់ដែលចុះឈ្មោះ នៅក្នុងមជ្ឈមណ្ឌលរបស់យើង ទទួលបានចំណីអាហាររបស់ពួកគេ ដោយគ្មានការយកកម្រៃអ្វីដាច់ដោយឡែកឡើយ ក៏ប៉ុន្តែ ការសម្រេចនៃកត្តាអាចទទួលបាននោះ ប៉ះពាល់ទៅលើចំនួននៃមូលនិធិ របស់រដ្ឋាភិបាលសហព័ន្ធ ដែលមជ្ឈមណ្ឌលយើង ទទួលបាន ។

ប្រសិនបើគ្រួសារលោកអ្នកប្រសិនបើគ្រួសារលោកអ្នកបច្ចុប្បន្ននេះ ទទួលប្រាក់កម្រៃពី:

- កម្មវិធី Food Stamp
- កម្មវិធីផ្តល់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រីក្រ(TANF) ឬ
- កម្មវិធីចែកចាយម្ហូបអាហារ នៅកន្លែងជនជាតិ INDIAN (FDPIR)

លោកអ្នកគ្រាន់តែត្រូវការកត់លេខករណីយ FOOD STAMP, កម្មវិធីផ្តល់ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារក្រីក្រ(TANF),កម្មវិធីចែកចាយម្ហូបអាហារ នៅកន្លែងជនជាតិ INDIAN (FDPIR) ឬ លេខកម្មវិធីដទៃទៀត នៅលើពាក្យសុំផលកម្រៃម្ហូបអាហារ (Meal Benefit Form) តែប៉ុណ្ណោះគ្រប់គ្រាន់ហើយ ។ លោកអ្នកក៏ចាំបាច់ត្រូវតែ ឲ្យមនុស្សធំពេញវ័យ ចុះហត្ថលេខា បំពេញថ្ងៃខែ ព្រមទាំងបំពេញលេខ SOCIAL SECURITY របស់ខ្លួន នៅលើពាក្យសុំផលកម្រៃម្ហូបអាហារ (Meal Benefit Form) ផងដែរ ឬមួយក៏ សរសេរថា “none” ប្រសិនបើមនុស្សធំពេញវ័យនោះ គ្មានលេខ SOCIAL SECURITY ទេនោះ ។ អ្នកផ្តល់ការថែទាំកូនតាមផ្ទះរបស់លោកអ្នក បន្ទាប់មក និងអាចទទួលបានប្រាក់កម្រៃកំរិតទី១ ច្រើនថែមទៀត សម្រាប់ម្ហូបអាហារ ដែលយកទៅចិញ្ចឹមកូនរបស់លោកអ្នកនោះ ។